

# ការងារអភិវឌ្ឍន៍ ប្រកបដោយច្នៃប្រឌិត និងចីរភាព

“មិនដូចភូមិផ្សេងៗទេ ព្រោះនៅក្នុងភូមិយើងមានគណៈកម្មាធិការការពារកុមារ។ អ្នកទាំងអស់គ្នាអាចរាយការណ៍ពីការព្រួយបារម្ភទាក់ទងនឹងកុមារណាមួយមកខ្ញុំបាន ព្រោះខ្ញុំជាសមាជិកគណៈកម្មាធិការម្នាក់ដែរ”។ ការលើកឡើងនេះ ធ្វើឡើងដោយអ្នកដឹកនាំពុទ្ធសាសនាម្នាក់ដែលគាត់បានជួយ និងឲ្យពរជ័យក្នុងពិធីបុណ្យពុទ្ធសាសនាមួយ។ អ្នកដឹកនាំសាសនា គឺជាមនុស្សសំខាន់ និងមានការគោរពពីសង្គមកម្ពុជា ហើយជាគំរូដល់មនុស្សជាច្រើន។

គម្រោងសម្លេងកុមាររបស់អង្គការអាយស៊ីស៊ី (អាយស៊ីស៊ី-វីអូធីស៊ី) កំពុងសម្របសម្រួលដំណើរការបង្កើតគណៈកម្មាធិការការពារកុមារ(គ.ក.ក)។ គ.ក.ក បង្កើតដោយពួកជំនុំព្រះវិហារ ដោយមានកិច្ចសហការជាមួយភាគីសង្គមស៊ីវិលដ៏ទៃទៀត។ គ.ក.ក ជាអង្គការសហគមន៍មូលដ្ឋាន( CBO ) ដែលត្រូវបង្កើតឡើងក្នុងភាពជាម្ចាស់របស់ប្រជាពលរដ្ឋមូលដ្ឋាន ដោយមានគោលបំណងស្នូលក្នុងការការពារកុមារ។ នេះមានន័យថា ជាការលើកកម្ពស់សិទ្ធិកុមារ និងការការពារកុមារ ហើយលើសពីនេះទៀត គឺដោះស្រាយបញ្ហាសង្គម និងការអភិវឌ្ឍក្នុងស្រុក។ គ.ក.ក ក៏លើកសម្លេងរបស់កុមារឲ្យកាន់តែទូលំទូលាយថែមទៀត ហើយបង្ហាញពីការប្តេជ្ញាចិត្ត និងបំណងចិត្តក្នុងការបង្កើតបរិយាកាសសុវត្ថិភាព និងស្ថានភាព សម្រាប់កុមារនៅក្នុងប្រទេសកម្ពុជា។

គ.ក.ក មានសមាជិកអចិន្ត្រៃយ៍ដែលតំណាងឲ្យប្រជាពលរដ្ឋនៅក្នុងភូមិ។ សមាជិកទាំងនោះ រួមមានឪពុកម្តាយ កុមារ យុវជន អ្នកដឹកនាំនៅតាមព្រះវិហារ អ្នកដឹកនាំខាងពុទ្ធសាសនា និងអ្នកតំណាងមកពីអង្គការសហគមន៍មូលដ្ឋានក្នុងស្រុក។ គ.ក.ក បានក្លាយជាជំណតភ្ជាប់រវាងសង្គមស៊ីវិលក្នុងស្រុក និងអាជ្ញាធរមូលដ្ឋាន ហើយនិងមន្ត្រីរដ្ឋាភិបាល ដើម្បីបង្កើតបណ្តាញ និងកិច្ចសហការសម្រាប់សុខុមាលភាពកុមារ។

រហូតមកដល់ពេលនេះ អាយស៊ីស៊ី-វីអូធីស៊ី បានគាំទ្រភូមិចំនួន១៧ក្នុងការបង្កើត គ.ក.ក របស់ពួកគេ នៅខេត្តពោធិ៍សាត់ និងខេត្តតាកែវ។ កុមារខ្លះបានសម្តែងនូវការពេញចិត្ត និងការដឹងគុណចំពោះប្រធានភូមិ អ្នកដឹកនាំព្រះវិហារ និងសមាជិក គ.ក.ក ផ្សេងទៀតដែលបានអនុញ្ញាតឲ្យពួកគេក្លាយជាសមាជិករបស់ គ.ក.ក។ កុមារទាំងនេះមើលឃើញថា ការចូលរួមនៅក្នុងការងារ ការពារកុមារនៅក្នុងភូមិរបស់ពួកគេផ្ទាល់ ជាឱកាសមួយសម្រាប់ពួកគេរៀនសូត្រ និងរីកចម្រើន។ អ្នកដឹកនាំព្រះវិហារ អ្នកដឹកនាំខាងពុទ្ធសាសនា ឪពុកម្តាយ និងប្រធានភូមិរបស់ពួកគេ ពិតជាមានការជម្រុញលើកទឹកចិត្ត និងមានមោទនភាពណាស់ចំពោះប្រយោជន៍ និងការចូលរួមរបស់កុមារ និងយុវជនដែលជាសមាជិករបស់ គ.ក.ក។

ទោះជាយ៉ាងណាក៏ដោយ ដំណើរការនៃការបង្កើត គ.ក.ក ក៏ប្រឈមនឹងបញ្ហាផងដែរ។ វាមិនតែងតែដំណើការទៅដូចដែលបានគ្រោងទុក និងរំពឹងទុកនោះទេ។ សមាជិក គ.ក.ក ចាំបាច់ត្រូវការការលើកទឹកចិត្ត និងការចូលរួម សម្រាប់បុព្វហេតុ និងមើលឃើញពីចក្ខុវិស័យនៃជីវភាពរស់នៅ និងស្ថានភាពសង្គមសម្រាប់កុមារ។ អាយស៊ីស៊ី-វីអូធីស៊ី រំពឹងថានឹងប្រើប្រាស់ គ.ក.ក ទាំង១៧ដំបូងនេះ ដើម្បីក្លាយជាគណៈកម្មការដែលជម្រុញលើកទឹកចិត្ត និងជាគំរូសម្រាប់ភូមិគោលដៅដទៃទៀតដែល អាយស៊ីស៊ី-វីអូធីស៊ី មានគម្រោងរៀបចំ គ.ក.ក ផងដែរ។

ការការពារកុមារ គឺជាការចាំបាច់នៅទូទាំងពិភពលោក ហើយ គ.ក.ក នៅកម្ពុជា គឺជាយានឬមធ្យោបាយមួយសម្រាប់ប្រជាជនក្នុងស្រុកដើម្បីមើលថែរក្សាកុមារនៅក្នុងសហគមន៍មូលដ្ឋាន។

កាលបរិច្ឆេទ៖ តុលា ២០១៧